ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ 157 [illegible] - កសក

# សារាចរ

# ស្តីពី

# វិធានការគ្រប់គ្រង និង ទប់ស្កាត់

# នូវការអនាធិបតេយ្យចលនាសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

---

ដើម្បីពង្រឹងការអនុវត្តន៍អនុក្រឹត្យលេខ ១៤ អនក្រ. ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ និង សារាចរណែនាំលេខ ០២៩ កសក.សរណន ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៨៩ ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ១៤ អនក្រ. ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ និង ដោយសង្កេតឃើញថា បច្ចុប្បន្ននេះជម្ងឺសត្វបានកើតមានឡើង និង ឆ្លងរាលដាលពីតំបន់មួយទៅតំបន់មួយទៀត ក៏ដូចជាមានអំពើចោរកម្មលួចសត្វគោ-ក្របីរបស់ប្រជាកសិករកាន់តែមានសន្ទុះខ្លាំងក្លាឡើងផងនោះ ដូច្នេះដើម្បីទប់ស្កាត់ជម្ងឺសត្វ និង អំពើចោរកម្មខាងលើសំដៅបង្កើនផលិតភាពកសិកម្ម ផលិតកម្មសត្វ និង កម្លាំងអូសទាញ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការណែនាំដល់នាយកដ្ឋានផលិតកម្ម បសុព្យាបាល និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត ក្រុងដូចខាងក្រោម :

- សហការជាមួយរដ្ឋបាល ឃុំ សង្កាត់ អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និង អង្គភាពពាក់ព័ន្ធ ដើម្បីទប់ស្កាត់ភាពអនាធិបតេយ្យនៃចលនាសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ។
- ចលនាសត្វគោ-ក្របី និង ផលិតផលមានដើមកំណើតពីសត្វនៅពេលយប់ចាប់ពីម៉ោង ២០ ដល់ម៉ោង ៥ ភ្លឺ ដោយគ្មានលិខិតអនុញ្ញាតពីសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ត្រូវហាមឃាត់ជាបណ្តោះអាសន្ន ។ ជនល្មើស និង វត្ថុតាងល្មើសច្បាប់ត្រូវឃាត់ទុកដើម្បីកសាងសំណុំរឿងតាមនីតិវិធី ។
- ពង្រឹងបន្ថែមលើការស្រាវជ្រាវ ត្រួតពិនិត្យនូវបរិមាណសត្វ សុខភាពសត្វ និង ធ្វើភិនសត្វ ដើម្បីរក្សា

និរន្តរភាពផលិតផលសត្វ ។

- កំណត់ទីកន្លែងប្រមូលទិញគោ-ក្របីជូនអាជីវករដែលបានទទួលគោលការណ៍នាំចេញ ឬ ប្រើប្រាស់ក្នុងស្រុក ។
- ត្រូវមានលិខិតអនុញ្ញាតពីសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាលក្នុងការដឹកជញ្ជូនគោ-ក្របីដោយភ្ជាប់មកជាមួយនូវភិនសត្វគោ-ក្របី និង លិខិតទិញ-លក់សត្វដែលមានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ សាមី ។
- ចលនាកសិករឱ្យយកចិត្តទុកដាក់ក្នុងការចិញ្ចឹមសត្វគោ-ក្របីជាលក្ខណៈគ្រួសារ សមូហភាព និង ជាលក្ខណៈពាក់កណ្តាលឧស្សាហកម្ម ដើម្បីបង្កើនចំណូលរបស់គ្រួសារ និង ចលនាកសិករក្នុងសហគមន៍ឱ្យចេះសហការគ្នាថែទាំសត្វគោ-ក្របីដែលជាកម្លាំងអូសទាញដ៏សំខាន់ក្នុងការបង្កបង្កើនផលកសិកម្ម ។

ទទួលបានសារាចរនេះ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចិត្ត-សារ៉ន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ